**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ២.១៤.០១៩.០២០.ប្រកាសព័ត៌មាន

ថ្ងៃព្រហស្បតិ៍ ១២ កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## ការចុះអនុស្សរណៈយោគយល់ស្តីពី ការលើកកម្ពស់ការទូទាត់និងការផ្ទេរប្រាក់ឆ្លងដែន រវាងធនាគារជាតិនៃកម្ពុជា និងធនាគារមេយប៊ែង

នៅថ្ងៃព្រហស្បតិ៍ ១២កើត ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជា បានចុះអនុស្សរណៈយោគយល់ជាមួយធនាគារមេយប៊ែង ដើម្បីជំរុញការទូទាត់និងការផ្ទេរប្រាក់ឆ្លងដែនរវាងប្រទេសកម្ពុជានិងម៉ាឡេស៊ី។ អនុស្សរណៈយោគយល់នេះត្រូវបានចុះហត្ថលេខាស្របពេលនឹងការរៀបចំពិធីខួប៨០ឆ្នាំនៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ។

តាមរយៈអនុស្សរណៈនេះ ធនាគារជាតិនៃកម្ពុជា ធនាគារមេយប៊ែងកម្ពុជា និងធនាគារ មេយប៊ែងម៉ាឡេស៊ី នឹងសហការគ្នាដើម្បីពិនិត្យលទ្ធភាពឱ្យប្រតិបត្តិការផ្ទេរប្រាក់និងទូទាត់ភ្លាមៗអាចធ្វើបានរវាងប្រទេសកម្ពុជានិងម៉ាឡេស៊ី តាមរយៈប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា និងវេទិកាឌីជីថលមេយប៊ែងធូយូ របស់ធនាគារមេយប៊ែង។

លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជាបានមានប្រសាសន៍ថា ការអភិវឌ្ឍប្រព័ន្ធបាគងនឹងផ្តល់លទ្ធភាពយ៉ាងច្រើនក្នុងការលើកកម្ពស់ប្រព័ន្ធទូទាត់ឱ្យកាន់តែប្រសើរឡើងទាំងក្នុងប្រទេសកម្ពុជានិងក្នុងកម្រិតតំបន់ ហើយអនុស្សរណៈដែលបានចុះហត្ថលេខាថ្ងៃនេះនឹងនាំឱ្យស្ថាប័នទាំងពីរឈានដល់កិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុមួយកម្រិតទៀត ក្នុងការទាញយកផលប្រយោជន៍បន្ថែមទៀតពីការរីកចម្រើនផ្នែកបច្ចេកវិទ្យាសម្រាប់បម្រើឱ្យប្រជាជនក្នុងប្រទេសកម្ពុជានិងម៉ាឡេស៊ី។ កិច្ចសហប្រតិបត្តិការនេះនឹងរួមចំណែកយ៉ាងច្រើនក្នុងការជំរុញសកម្មភាពពាណិជ្ជកម្មនិងបរិយាបន្នហិរញ្ញវត្ថុរវាងប្រទេសទាំងពីរ។

លោក Datuk Hamirullah Boorhan នាយកនាយកដ្ឋានសេវាហិរញ្ញវត្ថុសហគមនៃធនាគារមេយប៊ែងម៉ាឡេស៊ីបានលើកឡើងថា ធនាគារមេយប៊ែងពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានក្លាយជាដៃគូចុះអនុស្សរណៈដំបូងជាមួយធនាគារជាតិនៃកម្ពុជាក្នុងការលើកកម្ពស់ការទូទាត់និងផ្ទេរប្រាក់ឆ្លងដែនដោយប្រើប្រព័ន្ធបាគង។ តាមរយៈការតភ្ជាប់ក្នុងតំបន់អាស៊ាន និងវេទិកាឌីជីថលមេយប៊ែងធូយូ ធនាគារមេយប៊ែងនឹងផ្តល់សេវាផ្ទេរប្រាក់ឆ្លងប្រទេស កាន់តែមាន

ប្រអប់សំបុត្រលេខ ២៥, ម្ចាស់លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ភាពងាយស្រួល និងតម្លៃសមរម្យបន្ថែមទៀតជូនអតិថិជនរបស់ខ្លួននៅប្រទេសកម្ពុជានិងម៉ាឡេស៊ី។ ទន្ទឹមនោះ កិច្ចសហប្រតិបត្តិការនេះនឹងរួមចំណែកដល់ធនាគារមេយប៊ែង ក្នុងការសម្រេចបាននូវគោលដៅរបស់ខ្លួនជា "ជម្រើសធនាគារឌីជីថល" នៅក្នុងតំបន់ផងដែរ។

លោក Dato' Mohd Hanif Suadi នាយកប្រតិបត្តិធនាគារមេយប៊ែង (ខេមបូឌា) ភីអិលស៊ី បានមានប្រសាសន៍ថា ធនាគារមេយប៊ែងមានគោលដៅបំពេញតម្រូវការអតិថិជនដែលតែងតែមានការផ្លាស់ប្តូរតាមរយៈការវិវឌ្ឍន៍ខ្លួនជាបន្តបន្ទាប់ស្របតាមនវានុវត្តឌីជីថល ដើម្បីបម្រើអតិថិជនកាន់តែរហ័ស ងាយស្រួលនិងមានសុវត្ថិភាព។ កិច្ចសហប្រតិបត្តិការនេះនឹងជំរុញឱ្យធនាគារមេយប៊ែងខិតខំធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវារបស់ខ្លួនដល់អតិថិជនកាន់តែទូលំទូលាយជាមួយនឹងសេវាឌីជីថលផ្សេងៗ ដែលជាការរួមចំណែកដល់ការអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា។

បន្ទាប់ពីដាក់ឱ្យដំណើរការ សេវានេះនឹងរំពឹងថាផ្តល់ផលប្រយោជន៍ដល់ប្រជាជនកម្ពុជាដែលកំពុងរស់នៅប្រទេសម៉ាឡេស៊ី និងប្រជាជនម៉ាឡេស៊ីដែលកំពុងរស់នៅប្រទេសកម្ពុជា ក៏ដូចជាធុរកិច្ចក្នុងប្រទេសទាំងពីរ ដោយប្រើប្រាស់អ៊ីវ៉ាឡេតរបស់ប្រព័ន្ធបាគងនិងផ្លែតហ្វមឌីជីថលមេយប៊ែងធូយូ ដើម្បីផ្ទេរមូលនិធិឆ្លងប្រទេស សម្រាប់ការទូទាត់ពាណិជ្ជកម្ម និងការផ្ទេរប្រាក់។ កិច្ចសហប្រតិបត្តិការនេះនឹងជួយលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងកិច្ចគាំទ្រចំពោះការវិវឌ្ឍន៍ទៅរកសង្គមឌីជីថលក្នុងប្រទេសកម្ពុជា។

**ទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
លេខទូរស័ព្ទ៖ (៨៥៥) ៨៨ ៥៦៧០១៦៨/ (៨៥៥) ៨១ ៩០០៨៥១
Email៖ nbccommunication@nbc.org.kh / psd@nbc.org.kh